# មុននិងក្រោយវត្តមានរបស់កងទ័ពសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត នៅអាហ្វហ្គានីស្ថាន

ដោយ៖ លោក អ៊ុច លាង អ្នកសិក្សាស្រាវជ្រាវនៃនាយកដ្ឋានសិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា
នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា

*សង្គ្រាមវាយដណ្ដើមកាន់កាប់ដឹកដីអាហ្វហ្គានីស្ថានកើតឡើងវិញ ពីសំណាក់ក្រុមតាលីបង់ ចាប់តាំងពី សហរដ្ឋអាមេរិកនិងក្រុមសម្ព័ន្ធមិត្តប្រកាសដកកងទ័ព ទ្រង់ទ្រាយធំចេញពីអាហ្វហ្គានីស្ថាន ដែលរហូតមកទល់ពេលនេះ ក្រុមតាលីបង់បានខិតជិតដល់ក្រុងកាប៊ុលទៅហើយ។ អវត្តមានកងទ័ព លោកខាងលិចគឺហាក់បីដូចជាការបើកផ្លូវឱ្យក្រុមឧទ្ទាមតាលីបង់ ត្រឡប់ចូលទៅកាន់អំណាចវិញ ហើយវានឹងអាចហុចផលប្រយោជន៍ដល់ក្រុមអាល់កៃដាផង។ ពួកអាល់កៃដា ដែលត្រូវបានក្រុមតាលីបង់ផ្ដល់ជម្រកដ៏រឹងមាំ មុនការវាយប្រហារភេរវកម្មទៅលើទីក្រុងញូវយ៉ក និងវ៉ាស៊ីនតោនកាលពីថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០១ ដែលជាដើមហេតុនៃចំណុចចាប់ផ្ដើម ដែលនាំឱ្យសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តលោកខាងលិច ផាកទៅរកសង្គ្រាមដ៏ធំអស់រយៈពេល២០ឆ្នាំ នៅអាហ្វហ្គានីស្ថាន។ សូមរំលឹកថា សហរដ្ឋអាមេរិកនិងក្រុមសម្ព័ន្ធមិត្ត បានចាប់ផ្ដើមដកកងទ័ពរបស់ខ្លួន តាំងពីខែឧសភា ទៅតាមកិច្ចព្រមព្រៀងជាមួយពួកតាលីបង់ ដែលបានសន្យាថា នឹងមិនអនុញ្ញាតឱ្យពួកភេរវនិយមប្រើប្រាស់ទឹកដីអាហ្វហ្គានីស្ថានដើម្បីវាយប្រហារសហរដ្ឋអាមេរិក។ ពួកតាលីបង់បានសន្យាផងដែរថា នឹងចរចាសន្តិភាពជាមួយរដ្ឋាភិបាលអាហ្វហ្គានីស្ថាន។*

*តើនេះជាការបោះបង់អាហ្វហ្គានីស្ថាន ឬដោយសារតែសហរដ្ឋអាមេរិកជឿទុកចិត្តក្រុមតាលីបង់ ឬជាការធ្វេសប្រហែសរបស់សហរដ្ឋអាមេរិក?*

២០ឆ្នាំកន្លងទៅ នៃព្រឹត្តិការណ៍ ភេរវកម្មលើទឹកដីសហរដ្ឋអាមេរិក ពីសំណាក់ក្រុមអាល់កៃដា កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០១ ដែលជាដើមហេតុនៃចំណុចចាប់ផ្ដើម ដែលនាំឱ្យសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តលោកខាងលិច ផាកទៅរកសង្គ្រាមដ៏ធំអស់រយៈពេល ២០ឆ្នាំ នៅអាហ្វហ្គានីស្ថាន។ ពេលនេះ ការដកកងទ័ពរបស់សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត មិនទាន់បានប៉ុន្មានផង ក្រុមតាលីបង់ ដែលត្រូវបានគេស្គាល់ថាជាក្រុមដែលផ្ដល់ទីជម្រកដ៏រឹងមាំឱ្យក្រុមអាល់កៃដា បានបើកការវាយលុកក្នុងទ្រង់ទ្រាយធំ ដែលស្ទើរតែអាចគ្រប់គ្រងក្រុងកាប៊ុលទៅហើយ។

នៅចំពោះមុខ ការដកទ័ពអាមេរិកពីអាហ្វហ្គានីស្ថាន តាមរយៈរដ្ឋមន្ត្រីការបរទេសរបស់សហព័ន្ធរុស្ស៊ី បានសំដែងក្ដីបារម្ភ ពីគ្រោះថ្នាក់របស់ក្រុមជីហាតរដ្ឋអ៊ីស្លាម ដែលកំពុងពង្រីកដែនឥទ្ធិពលរបស់ខ្លួននៅភាគខាងជើងអាហ្វហ្គានីស្ថាន។ ក្រៅពីក្រុមជីហាត កងទ័ពរដ្ឋាភិបាលអាហ្វហ្គានីស្ថាន

កំពុងរងការវាយប្រហារផងដែរពីក្រុមតាលីបង់ដែលបានបង្កើនការប្រយុទ្ធដណ្តើមយកស្រុក និងប៉ុស្ត ត្រួតពិនិត្យពីកងទ័ពរដ្ឋាភិបាលនៅភាគខាងជើងប្រទេស។

ប្រទេសអង់គ្លេស នៅថ្ងៃសុក្រ ១៣សីហា បានចេញមុខរិះគន់ថាការដកកងទ័ពអាម៉េរិកចេញពីអាហ្វហ្កានីស្ថាន គឺជាកំហុសធ្ងន់មួយ។ ទន្ទឹមនេះ ទីក្រុងឡុងដ៍ ព្រមានផងដែរថា ការវិលត្រលប់មកវិញរបស់ចលនាឧទ្ទាមតាលីបង់ នឹងអាចបើកផ្លូវឱ្យមានការបង្កើតមូលដ្ឋានសម្រាប់ពួកជ្រុលនិយម ដែលជាការគំរាមកំហែងចំពោះពិភពលោក។

បញ្ហានេះមិនមានរាអ្វីប្លែកនោះទេ សម្រាប់គោលនយោបាយការបរទេស របស់មហាអំណាច គឺៈមិនមានមិត្តដ៏ស្មោះត្រង់ជាអមតៈ ឬ សត្រូវអចិន្ត្រៃយ៍ នោះឡើយ ផលប្រយោជន៍ជាតិតែមួយគត់ ដែលជាគោលការណ៍ដ៏ត្រឹមត្រូវ និងត្រូវធ្វើ គឺផលប្រយោជន៍ជាយុទ្ធសាស្ត្រទាំងនយោបាយ សេដ្ឋកិច្ច និងការទូត។

ការដកកងទ័ពរបស់សហរដ្ឋអាម៉េរិក និងសម្ព័ន្ធមិត្ត ចេញពីអាហ្វហ្កានីស្ថាន នាពេលបច្ចុប្បន្ន បានផ្តល់ឱកាសឱ្យក្រុមតាលីបង់ បានវាយដណ្តើមកាន់កាប់បានទីក្រុងជាច្រើន ក្នុងរយៈពេលត្រឹមតែមួយសប្តាហ៍ ហើយកម្លាំងតាលីបង់ បាននិងកំពុងតែបន្តរុលឆ្ពោះទៅកាន់កាប់រដ្ឋធានីកាប៊ុល ដើម្បីឈានទៅគ្រប់គ្រង មូលដ្ឋានទ័ព Bagram ស្ថិតនៅចម្ងាយ ៥០គីឡូម៉ែត្រ ពីទីក្រុងកាប៊ុល ដែលជាទីតាំងយុទ្ធសាស្ត្រ និងជាកន្លែងផ្គត់ផ្គង់សព្វាវុធដ៏សំខាន់របស់កងទ័ពបរទេស សម្រាប់ធ្វើសង្គ្រាមប្រយុទ្ធប្រឆាំងនឹងពួកតាលីបង់ អស់កាល២០ឆ្នាំមកនេះ។ គឺចេញពីមូលដ្ឋានទ័ពអាកាស Bagramនេះហើយ ដែលកងទ័ពរបស់អាមេរិកនិងអូតង់តែងបញ្ជូនយន្តហោះចម្បាំងទៅវាយប្រហារពួកតាលីបង់ និងដើម្បីឈានទៅគ្រប់គ្រងអំណាចទាំងស្រុងនៅអាហ្វហ្កានីស្ថាន។

សូមរំលឹកថា បន្ទាប់ពីកងទ័ពអាម៉េរិក និងសម្ព័ន្ធមិត្តដកខ្លួនចេញអស់ពីមូលដ្ឋាន Bagram កងទ័ពអាហ្វហ្កានីស្ថានជាអ្នកការពារ និងប្រើមូលដ្ឋានទ័ព Bagram ដើម្បីប្រយុទ្ធប្រឆាំងនឹងក្រុមភេរវនិយម។ កងទ័ពអាហ្វហ្កានីស្ថានប្រើប្រាស់មូលដ្ឋាន Bagram ជាចំណុចគន្លឹះសំខាន់ ដើម្បីធានាសន្តិសុខឱ្យតំបន់ជុំវិញរដ្ឋធានីកាប៊ូល និងដើម្បីដាក់សម្ពាធលើពួកតាលីបង់។

នេះបើយើងក្រឡេកទៅមើលកាលពីជៀង៤៥ឆ្នាំមុន នៃព្រឹត្តិការណ៍ដែលធ្លាប់បានកើតឡើងរួចមកហើយ នៅប្រទេសកម្ពុជា និងនៅប្រទេសវៀតណាមភាគខាងត្បូង កាលពីអំឡុងឆ្នាំ១៩៧៥ គឺមិនខុសប៉ុន្មានពីបញ្ហានៅអាហ្វហ្កានីស្ថាន នាពេលនេះទេ។

ឆ្នាំ១៩៧៥ ក្រោយពីសហរដ្ឋអាម៉េរិកប្រកាសដកកងទ័ពចេញពីសង្គ្រាមនៅឥណ្ឌូចិន។ ទីក្រុងភ្នំពេញត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ និងទ្រង់ស៊ីសុវត្ថិ សិរិមតៈ ដែលសហរដ្ឋអាម៉េរិកគាំទ្រ ត្រូវបានផ្តួលរំលំជាស្ថាពរ។ ទីក្រុងសៃហ្គន គ្រប់គ្រងដោយរដ្ឋាភិបាលសាធារណរដ្ឋវៀតណាមខាងត្បូង ដែលគាំទ្រដោយ

សហរដ្ឋអាម៉េរិក ក៏ត្រូវបានធ្លាក់ក្រោមការគ្រប់គ្រងរបស់វៀតណាមខាងជើង នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៧៥។ ឆ្នាំ១៩៧៥ ក្រោយប្រកាសដកខ្លួនចេញ សហរដ្ឋអាម៉េរិក មិនអាចជួយអ្វីដល់រដ្ឋាភិបាលសម្ព័ន្ធមិត្តរបស់ខ្លួនឡើយ ក្រៅពីបន្សល់ទុកកងកម្លាំងទ័ពបន្តិចបន្តួច ដើម្បីការពារមន្ត្រី និងបុគ្គលិកស្ថានទូតតែប៉ុណ្ណោះ។

វាក៏មិនប្លែកពីអ្វីពីសង្គ្រាមនៅឧបទ្វីបកូរ៉េ នៅឆ្នាំ១៩៤៩ សហភាពសូវៀត និងសហរដ្ឋអាម៉េរិក បានព្រមព្រៀងគ្នាដកកងទ័ពរៀងៗខ្លួនចេញពីកូរ៉េ ដោយបន្សល់ទុកនូវប្រទេសពីរ ដែលមានកំណើតចេញពីសាច់ឈាមនៃជាតិសាសន៍តែមួយ តែសំឡឹងមើលគ្នាក្នុងភាពជាសត្រូវ ។ ក៏ប៉ុន្តែ ក្រោយពីសហរដ្ឋអាម៉េរិកដកកងទ័ពចេញទៅ កូរ៉េខាងត្បូងមានកងទ័ពមិនដល់ ១០ម៉ឺននាក់ផង ហើយកងទ័ពនោះទៀតសោត ក៏មិនសូវមានការហ្វឹកហ្វឺនខ្ពស់ ហើយភាគច្រើនមានបទពិសោធន៍ខាងបេសកកម្មរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងស្រុក ជាជាងបទពិសោធន៍ខាងប្រយុទ្ធ។ ផ្ទុយពីសហរដ្ឋអាម៉េរិក សហភាពសូវៀតបានដកថយចេញពីកូរ៉េ ដោយបន្សល់ទុកនូវកងទ័ព  កូរ៉េខាងជើងចំនួន ១៣ម៉ឺន ៥ពាន់នាក់ ដែលទទួលបានការហ្វឹកហ្វឺន និងបទពិសោធន៍ខ្ពស់ ព្រមទាំងបំពាក់ទៅដោយគ្រឿងសព្វាវុធទំនើបៗ រួមមាន រថក្រោះ កាំភ្លើងធំ និងប្រព័ន្ធកាំជ្រួចទំនើបៗ។  សហភាពសូវៀតក៏បានរក្សាទុកផងដែរនូវជំនាញការយោធាឱ្យនៅជួយកងទ័ពកូរ៉េខាងជើង។ ពិសេសជាងនេះទៅទៀត បានបន្សល់ទុកនូវ សង្គ្រាមនៅឧបទ្វីបកូរ៉េរហូតមកទល់ពេលនេះ។

តែបើត្រឡប់ទៅមើលពីបញ្ហា សង្គ្រាមរវាងបក្សកុម្មុយនិស្តចិន ដែលដឹកនាំដោយលោក ម៉ៅសេទុង (Mao Tsé-Toung) និងសាធារណរដ្ឋចិនដែលពេលនេះស្ថិតនៅកោះតៃវ៉ាន់ ដែលដឹកនាំដោយ ចាង កៃឆេក គឺមិនខុសពីស្ថានភាពរបស់អាហ្វហ្គានីស្ថាននាពេលនេះនោះទេ។ នៅអំឡុងសង្គ្រាមលោកលើកទី២ លោក ចាង កៃឆេក ដែលជាមេដឹកនាំក្រុមសាធារណរដ្ឋចិន បានទទួលបានជំនួយពីអាម៉េរិក និងមានចំនួនកងទ័ពយ៉ាងច្រើន ប៉ុន្តែជាកងទ័ពដែលទន់ខ្សោយ ដោយសារមេទ័ពរបស់ក្រុមនោះ ត្រូវបានតែងតាំងនិងដំឡើងឋានៈតាមរយៈបក្ខពួកនិយម ដោយមិនខ្វល់ពីសមត្ថភាព នាំឱ្យកើតមានអំពើពុករលួយពាសពេញនៅក្នុងជួរកងទ័ព។ មេទ័ពភាគច្រើននាំគ្នាបំប៉ោងចំនួនកូនទាហាន ព្រមទាំងឆ្មៀតកាត់របបទាហាន ដោយទុកឱ្យកូនទាហាន នៅតាមសមរភូមិខ្វះស្បៀង និងខ្វះគ្រឿងសព្វាវុធ។

នាថ្ងៃទី១៥ ខែសីហា ក្រោយពេលពួកតាលីបង់ បានវាយដណ្តើមកាន់កាប់ទីក្រុង Jalalabad រួចហើយ ពួកគេក៏បានបន្តបង្កើនល្បឿនយ៉ាងលឿន ឆ្ពោះទៅកាន់កាប់រដ្ឋធានីកាប៊ូល ប្រទេសអាហ្វហ្គានីស្ថាន ហើយបានឈានទៅគ្រប់គ្រងទីក្រុងកាប៊ុល និងបានកាន់កាប់តំបន់ជាច្រើន រួមទាំងអតីតអាកាសយានដ្ឋានសហរដ្ឋអាមេរិក នៅ Bagram និងចូលទៅកាន់វិមានរដ្ឋាភិបាល ក្រោយពេលលោក Ashraf Ghani ប្រធានាធិបតីអាហ្វហ្គានីស្ថាន បានភៀសខ្លួន ចេញពីប្រទេស។

ក្រោយផ្ដួលរំលំរដ្ឋាភិបាលក្រុងកាប៊ុល មេដឹកនាំក្រុមប្រដាប់អាវុធនេះ នឹងប្រកាសដាក់ឈ្មោះប្រទេសអាហ្គានីស្ថានបច្ចុប្បន្ន ទៅជាអ៊ិស្លាមអេមីរ៉េតអាហ្វហ្គានីស្ថាន ក្នុងពេលដ៏ឆាប់ៗ។

ជាសរុបមក ការផ្ដួលរំលំ រដ្ឋាភិបាលក្រុងកាប៊ុល ពីសំណាក់ក្រុមតាលីបង់ នាពេលនេះ បង្ហាញថាការរីកចម្រើននៃចលនាសាសនាអ៊ីស្លាមជ្រុលនិយម កាន់តែខ្លាំងឡើងៗ បានធ្វើឱ្យពិភពលោកទាំងមូលមានការព្រួយបារម្ភណ៍។ យ៉ាងណាមិញ ក្រុមតាលីបង់គឺមានភាពល្បីល្បាញ ពីភាពឃោរឃៅ និងការអនុវត្តន៍អ៊ីស្លាមតាមបែបអ៊ីស្លាមជ្រុលនិយម អស់រយៈពេលប្រាំឆ្នាំក្នុងអំឡុងក្រោមការគ្រប់គ្រងរបស់ពួកគេ រហូតដល់ត្រូវបានផ្ដួលរំលំ ដោយមានការធ្វើអន្តរាគមន៍ ដែលដឹកនាំដោយសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០១។

ដូច្នេះការដកខ្លួនរបស់សហរដ្ឋអាម៉េរិក និងក្រុមសម្ព័ន្ធមិត្ត នាពេលនេះនឹងអាចបង្កហានិភ័យដល់ប្រជាពលរដ្ឋអាហ្វហ្គានីស្ថាបនិយាយដោយឡែក និងជារួមដល់ប្រជាជាតិទាំងមូល។ ព្រោះថាបើពិនិត្យមើលពី បញ្ហាសិទ្ធិមនុស្សនៅអាហ្វហ្គានីស្ថានៈ ក្រុមតាលីបង់ កាលអតីតកាល គឺហាមឃាត់ស្ត្រីមិនឱ្យទទួលបានការអប់រំ ប្រព្រឹត្តអំពើឃើរឃៅ បង្ក្រាបក្រុមជនជាតិភាគតិចដូចជា Shiite Hazara និងបានបំផ្លាញរូបចម្លាក់ព្រះពុទ្ធបុរាណ សាងអំពីថ្ម ធំបំផុត និងមានតម្លៃមហាសាលនៅ Bamiyan។ មួយវិញទៀត បើអាហ្វហ្គានីស្ថានត្រូវត្រឡប់ទៅស្ថិតក្រោមការគ្រប់គ្រង របស់ក្រុមតាលីបង់វិញ នឹងអាចក្លាយជាជម្រករបស់ពួកជ្រុលនិយម អាចជាកន្លែងជម្រករបស់ក្រុម អាល់កៃដា និង IS ដែលបង្កមហន្តរាយដល់មនុស្សជាតិទាំងមូល៕